# របាំពួយសួយ

«របាំពួយសួយ» មានឈ្មោះដូច្នេះដោយសាររបាំនេះត្រូវគេកំដរដោយឧបករណ៍តន្ត្រីពួយជាគោល ដែលមានបំពង់សួរធ្វើពីឫស្សីពកចំនួនពីរ បី ឬប្រាំ រហូតដល់ប្រាំពីរ ស៊កចូលទៅក្នុងប្រអប់សូរធ្វើពីផ្លែឃ្លោកស្ងួតធ្លាយពីម្ខាងទៅម្ខាង ដោយចងផ្ដុំគ្នាជាមួយជុំដោយចម្រៀកផ្ដៅ។ ឧបករណ៍ពួយ មានប្រើនៅក្នុងចំណោមជនជាតិដើមភាគតិចសួយ រស់នៅក្នុងតំបន់ជួរភ្នំក្រវាញ មានសហគមន៍សួយត្រាង ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺជាដើម។

គេសម្ដែងរបាំពួយសួយ នៅក្នុងពិធីសែនព្រេន បន់អ្នកតានិងឡើងអ្នកតា បួងសួងសុំសេចក្ដីសុខសួស្ដីសិរីមង្គលឱ្យរួចផុតពីគ្រោះចង្រៃនិងមហន្តរាយផ្សេងៗ និងដើម្បីរំឭកទៅដល់ដើមកំណើតនៃពេលវេលានិងការវិលត្រឡប់នៃនិរន្តរភាព។ ឯវង់តន្ត្រីកំដររបាំពួយសួយ មានឧបករណ៍ពួយ ប្រើជាមួយនឹងស្គរ និងអ្នកច្រៀង។

ក្នុងសហគមន៍ជនជាតិភាគតិចខាងលើ គឺគេនៅបន្តបដិបត្តិទំនៀមទម្លាប់ប្រពៃណីដូនតាបុរាណនេះនៅឡើយ ជាពិសេសនៅក្នុងចំណោមចាស់ៗ។ ចំណែកឯក្មេងៗសួយជំនាន់ឥឡូវ ហាក់ដូចជាពុំបានយកចិត្តទុកដាក់រៀនសូត្រនិងបន្តទំនៀមទម្លាប់ប្រពៃណីដូនតាបុរាណនេះឡើយ ដែលជាការគួរព្រួយបារម្ភណ៍មួយចំពោះវាសនាអនាគតនៃវប្បធម៌ជនជាតិដើមបុរាណនេះ។

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង





អត្ថបទដោយៈ បណ្ឌិត សំ សំអាង



## ឯកសារពិគ្រោះ

សំ ចន្ទ្រមូលី, ង៉ួន សំអាត, និង សំ សំអាង. (១៩៩៨). *របាំប្រពៃណីខ្មែរ* (បោះពុម្ពលើកទី ២). វ៉ាស៊ិងតោន: សភាសម្ព័ន្ធខ្មែរ។

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង